ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខ D381/3

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
19 / 07 / 2019
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ:**

**សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពន្យារកាលបរិច្ឆេទសម្រាប់ការជូនដំណឹង អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង 004**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda J. HOLLIS
(បម្រុង)

**សហមេធាវីតំណាងអ្នកដាក់ពាក្យសុំ**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួល "សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ" ចុះថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០១៩[1] ("សំណើ") និង "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ យឹម ទិត្យ សុំពន្យារពេលកាលបរិច្ឆេទកំណត់សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ D381 & D382 (D381/1 & D382/1)" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩[2] ("ចម្លើយតប")

1. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នានៅក្នុងសំណុំរឿង ០០៤។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចរបស់គាត់លើកលែងចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ[3] ជាភាសាខ្មែរ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយរបស់គាត់ជាភាសាអង់គ្លេស[4] (ជារួមហៅថា ដីកាដំណោះស្រាយ)។ សំណៅបកប្រែឯកសារទាំងពីរនេះ ពុំទាន់បញ្ចប់នៅឡើយទេ។

2. នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ សហមេធាវីការពារក្ដី យឹម ទិត្យ បានដាក់សំណើសុំពន្យារកាលបរិច្ឆេទដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ[5]។

3. នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន។

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១) ("សំណុំរឿង ០០៤ (អបជ៦១") សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/1 និង D382/1 ("សំណើ").

[2] សំណុំរឿង ០០៤ (អបជ៦១) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ យឹម ទិត្យ សុំពន្យារពេលកាលបរិច្ឆេទកំណត់សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ D381 & D382 (D381/1 & D382/1)" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/2 និង D382/2 ("ចម្លើយតប")។

[3] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។

[4] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

[5] សំណើ កថាខណ្ឌ ៦។

4. សហមេធាវីការពារក្តី យឹម ទិត្យ ស្នើសុំឲ្យអង្គបុរេជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អនុលោមតាមវិធាន ៣៩(២) និង (៤) ដើម្បីពន្យារពេលកំណត់ដាក់ការជូនដំណឹងរបស់ យឹម ទិត្យ អំពី បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ពី ១០ ថ្ងៃ ទៅ ១៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលក្រុមមេធាវីការពាក្តីបានទទួលឯកសារបកប្រែនៃដីកាដំណោះស្រាយទាំពីរ[6]។ សហមេធាវីជំទាស់ថា សំណៅបកប្រែពេញលេញនៃដីកាដំណោះស្រាយទាំងពីរជាភាសាអង់គ្លេស និងជាភាសាខ្មែរ ជាការចាំបាច់ណាស់ដើម្បីធានាថា មេធាវីការពារក្តីទទួលបាននូវដីកាដំណោះស្រាយទាំងពីរជាភាសាដែលខ្លួនយល់ច្បាស់ និងធ្វើការសម្រេចអំពីបណ្តឹងឧទ្ធរណ៍បន្ទាប់ពីទទួលបានព័ត៌មានពេញលេញ ដោយពិចារណាទៅលើខ្លឹមសារ និងទំនាក់ទំនងនៃដីកាដំណោះស្រាយទាំងពីរ និងលក្ខខណ្ឌតម្រូវនៃការប្តឹងឧទ្ធរណ៍[7]។ ចុងក្រោយ សហមេធាវីកត់សម្គាល់ថា ដីកាដំណោះស្រាយទាំងពីរបូកបញ្ចូលគ្នា មានចំនួនជាង ១.០០០ សន្លឹក ទាំងផ្នែកច្បាប់ និងអង្គហេតុ[8]។

5. សហព្រះរាជអាជ្ញាឆ្លើយតបថា ខ្លួនពុំជំទាស់ទៅនឹងសំណើរបស់ យឹម ទិត្យ ដែលស្នើសុំពន្យារកាលបរិច្ឆេទពី ១០ ថ្ងៃ ទៅ ១៥ ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងអំពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ ក្នុងលក្ខខណ្ឌដែលថា ការពន្យារពេលត្រូវផ្តល់ឲ្យស្មើគ្នាដល់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិផងដែរ[9]។

6. អនុលោមតាមវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងក្នុងអំឡុងពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីជូនដំណឹងអំពីដីកា ឬសេចក្តីសម្រេចជាភាសាខ្មែរ និងជាភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក[10]។

---

[6] សំណើ កថាខណ្ឌ ៦។

[7] សំណើ កថាខណ្ឌ ៥។

[8] សំណើ កថាខណ្ឌ ៤-៥។

[9] ចម្លើយតប កថាខណ្ឌ ១។

[10] វិធានផ្ទៃក្នុង ៧៥(១), សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក អ.វ.ត.ក/០១/២០០៧/វ.០៨ ដែលបានធ្វើវិសោធនកម្មថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២។

ទោះបីជាយ៉ាងណាក៏ដោយ អនុលោមតាមវិធាន ៣៩(២) និង (៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចកំណត់ និង/ឬបន្ថែមពេលវេលាណាមួយសម្រាប់ការដាក់ឯកសារទាំងឡាយទាក់ទងទៅនឹងបណ្ដឹងឧទ្ធរណ៍។

7. អង្គបុរេជំនុំជម្រះយល់ឃើញថា ភាគីគួរតែមានលទ្ធភាពពិនិត្យមើលទៅលើដីកាដំណោះស្រាយទាំងពីរជាភាសាដែលខ្លួនយល់ដឹងច្បាស់លាស់ មុនពេលខ្លួនធ្វើការសម្រេចណាមួយពាក់ព័ន្ធនឹង ការប្ដឹងឧទ្ធរណ៍។ លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ទៅលើកម្រាស និងភាពស្មុគស្មាញនៃដីកាដំណោះស្រាយ រួមជាមួយនឹងវិសាលភាព និងសេចក្ដីសំខាន់នៃបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ព្រមទាំងកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការរក្សាតុល្យភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស។ ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការផ្ដល់ឲ្យភាគីទាំងអស់នូវការពន្យារពេលរហូតដល់ដប់បួនថ្ងៃ ដើម្បីដាក់ការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់ខ្លួនបន្ទាប់ពីមានការជូនដំណឹងអំពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ គឺជាការសមហេតុផល។

**យោងតាមសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ទទួលយក** សំណើនេះ។

**បង្គាប់ឲ្យ**

ភាគីទាំងអស់ដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ នៅក្នុងរយៈពេលដប់បួនថ្ងៃ បន្ទាប់ពីមានការជូនដំណឹងអំពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរនេះ។

**រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩**

PRE-TRIAL CHAMBER E.C.C.C

ប្រធាន អង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន Olivier BEAUVALLET ន័យ ថុល Kang Jin BAIK ហួត វុទ្ធី